## គម្រោងនៃការចូលរួមរបស់ជនរងគ្រោះ

វាមានសារៈសំខាន់ណាស់ដែលជនរងគ្រោះបានដឹងអំពីឱកាសក្នុងការចូលរួមនៅក្នុងដំណើរការ ជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ តួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺផ្តល់ដល់ជនរងគ្រោះ នូវពត៌មានទាំងអស់ដែលពួកគេត្រូវដឹងមុននឹងធ្វើការសម្រេចចិត្តចូលរួមក្នុងដំណើរការនេះ ។ ការទទួល បានពត៌មាននេះគឺជាការរួមចំណែកមួយយ៉ាងសំខាន់នៅក្នុងដំណើរការផ្សះផ្សាជាតិ ។ ជនរងគ្រោះ មានសិទ្ធិសម្រេចមិនព្រមចូលរួម ហើយការសម្រេចចិត្តនេះត្រូវតែគោរព ។ ដោយសារមូលហេតុនេះ គ្មានជនរងគ្រោះណាម្នាក់ត្រូវបានជំរុញឲ្យចូលរួមទេ ប្រសិនបើពួកគេមានដាក់លក្ខ័ណ្ឌផ្សេងៗ ។

### សារៈសំខាន់នៃការគ្រប់គ្រងការរំពឹងទុក

នៅពេលដែលជនរងគ្រោះសម្រេចចិត្តចូលរួម វាមានសារៈសំខាន់ណាស់ដែលយើងត្រូវធ្វើ តាមដែលអាចធ្វើទៅបាន ក្នុងការគ្រប់គ្រងការរំពឹងទុករបស់គាត់ ដើម្បីកុំឲ្យគាត់បាត់បង់ជំនឿចិត្ត នៅក្នុងដំណើការនេះ ។ ឧទាហរណ៍ មនុស្សភាគច្រើននឹងមិនត្រូវបានជ្រើសរើសធ្វើជាសាក្សីទេ ។ ពាក្យបណ្តឹង និងបណ្តឹងសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណី នឹងទំនងជាត្រូវប្រានចោល ឬបដិសេធន៍ចោល ។ ដូច្នេះ យើងចាំបាច់ត្រូវពន្យល់ប្រាប់ជនរងគ្រោះថា នៅពេលមានការប្រានចោលនេះ វាមិនមែន មានន័យថា ពត៌មានដែលគាត់បានផ្តល់ឲ្យ ឬការរងគ្រោះដែលគាត់ទទួលរង មិនមានសារៈសំខាន់ នោះទេ ។ វាគ្រាន់តែមានន័យថា ដោយសារតែអង្គជំនុំជម្រះវិសាមញ្ញមានធនធាន និងពេលវេលា មានកំណត់ រឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់នឹងមិនត្រូវបានលើកយកមកពិភាក្សាដោយអង្គជំនុំជម្រះ វិសាមញ្ញទេ ។ ប៉ុន្តែ សំណើរសុំចូលរួមរបស់គាត់នឹងក្លាយជាផ្នែកមួយនៃឯកសារប្រវត្តិសាស្ត្រ និងរួម ចំណែកដល់ការយល់ដឹងអំពីអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ ជាងនេះទៅទៀត តាម រយៈការបំពេញទម្រង់នោះ គាត់អាចបញ្ចេញយោបល់អំពីសំណងជាសមូហភាព ឬជានិមិត្តរូបប្រភេទ ណាដែលគាត់ចង់បានពីអង្គជំនុំជម្រះវិសាមញ្ញ ។ ជនរងគ្រោះនឹងប្រាកដជាចង់ដឹងអំពីរបៀបដែល គាត់អាចចូលរួមអំពីផលប្រយោជន៍ និង អំពីកាតព្វកិច្ចដែលត្រូវបំពេញនៅក្នុងពេលចូលរួមនេះ និងអំពី ថាតើការការពារប្រភេទណាដែលគាត់អាចទទួលបានប្រសិនបើគាត់ចូលរួម ។ គារាងពត៌មានអំពីការ ចូលរួមដោយជនរងគ្រោះនេះគឺដើម្បី ឆ្លើយតបទៅនឹងសំណួរទាំងនេះ ។ ប៉ុន្តែ ដោយសារអង្គជំនុំជម្រះ វិសាមញ្ញគឺជាតុលាការថ្មីមានសំណួរជាច្រើនដែលមិនទាន់មានចម្លើយទេ រហូតដល់ពេលដែលសំណួរទាំង នេះត្រូវបានចោទសួរនៅក្នុងអង្គជំនុំជម្រះ ។ ដោយសារមូលហេតុនេះ វាមានសារៈសំខាន់ណាស់ដែល យើងត្រូវស្មោះត្រង់ជាមួយជនរងគ្រោះ និងប្រាប់គាត់ឲ្យបានដឹងថា យើងមិនមែនតែងតែអាចផ្តល់ ចម្លើយទៅឲ្យគាត់ទាំងអស់នោះទេ ។ នៅពេលដំណាលគ្នានេះដែរ យើងអាចត្រឹមតែបំពេញទម្រង់

ទៅតាមលទ្ធភាពរបស់យើងប៉ុណ្ណោះ ។ លោកអ្នកមិនចាំបាច់ព្រួយបារម្ភអំពីនិយមន័យច្បាប់ច្បាស់លាស់នោះទេ ។ វាអាស្រ័យទៅលើអង្គជំនុំជម្រះវិសាមញ្ញទេដែលជាអ្នកសម្រេចថាតើជនរងគ្រោះណាម្នាក់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចចូលរួមបាន ពោលគឺយើងមិនមែនជាអ្នកសម្រេចនោះទេ ។

នៅចុងបញ្ចប់ យើងត្រូវតែដឹងឲ្យបានច្បាស់លាស់អំពីតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងដំណើរការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថានឹង (១) ជូនពត៌មានដល់ជនរងគ្រោះអំពីសិទ្ធិចូលរួមរបស់គាត់ និង(២) ជួយអ្នករួចជីវិតក្នុងការចុះឈ្មោះជាមួយអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែ **មជ្ឈមណ្ឌលឯកសារកម្ពុជានឹងមិនផ្តល់តំណាងផ្នែកច្បាប់ ឬជំនួយជាបន្តបន្ទាប់ពេញរយៈពេលជំនុំជម្រះទាំងស្រុងនោះទេ ។**

## បំពេញទម្រង់សម្រាប់ការចូលរួមដោយជនរងគ្រោះ

តាមរយៈការបំពេញទម្រង់សម្រាប់ការចូលរួមដោយជនរងគ្រោះ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យអាចស្នើសុំចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការជំនុំជម្រះក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមរបៀបបីយ៉ាងៈ តាមរយៈការស្ម័គ្រចិត្តធ្វើជា**សាក្សី**, តាមរយៈការដាក់**ពាក្យបណ្តឹង**, និងតាមរយៈការដាក់ពាក្យចូលរួមជា«ជនរងគ្រោះ» នៅក្នុង**បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី** ។

### I. សាក្សី

ជនរងគ្រោះ ឬបុគ្គលណាម្នាក់ ដែលមានពត៌មានអាចជួយព្រះរាជអាជ្ញា ឬមេធាវីចុងចោទបញ្ជាក់ពីទោសកំហុស ឬភាពបរិសុទ្ធរបស់ជនជាប់ចោទណាម្នាក់ អាចត្រូវបានគេហៅថាជា«សាក្សី» ។ សាក្សីត្រូវ**ស្បថថានឹងនិយាយការពិត** ហើយ បន្ទាប់មក ត្រូវរៀបរាប់រឿងរ៉ាវដោយផ្ទាល់ទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញ ។ រឿងរ៉ាវរបស់គាត់នឹងក្លាយទៅជាផ្នែកមួយនៃឯកសារផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ អង្គជំនុំជម្រះវិសាមញ្ញនឹងជ្រើសរើសថាតើនរណានឹងធ្វើជាសាក្សីនៅក្នុងសំណុំរឿងនីមួយៗអាស្រ័យទៅតាមបទចោទប្រកាន់ និង ថាតើជនរងគ្រោះណាមួយដែលមានភស្តុតាងផ្ទាល់ និងពិស្តារ បញ្ជាក់ពីឧក្រិដ្ឋកម្មទាំងនោះ ។ ជនរងគ្រោះអាចស្ម័គ្រចិត្តធ្វើជាសាក្សីដោយបញ្ជាក់នៅក្នុង**ទម្រង់ពត៌មានជនរងគ្រោះ** ។ ជាងនេះទៅទៀត ប្រសិនបើអ្នករួចជីវិតណាម្នាក់ដាក់ពាក្យបណ្តឹងអំពីបទឧក្រិដ្ឋណាមួយ វាអាចដែលថា គាត់នឹងត្រូវបានគេអញ្ជើញឲ្យធ្វើសាក្សី ។ ផ្ទុយទៅវិញ សូម្បីតែជនរងគ្រោះម្នាក់ប្រាប់អង្គជំនុំជម្រះវិសាមញ្ញថា គាត់ចង់ធ្វើជាសាក្សីក៏ដោយ គាត់ប្រហែលជានឹងមិនត្រូវបានអញ្ជើញឲ្យទៅផ្តល់សក្ខីភាពនោះទេ ។ ជនរងគ្រោះតិចតួចណាស់ដែលនឹងត្រូវអញ្ជើញ ឲ្យធ្វើ

ជាសាក្សី ដូច្នេះជនរងគ្រោះគួរតែដឹងជាមុនថា គាត់មានឱកាសតិចតួចណាស់ដែលនឹងត្រូវ អញ្ជើញឲ្យធ្វើជាសាក្សី ។

ប្រសិនបើជនរងគ្រោះណាម្នាក់ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញជ្រើសរើសធ្វើជាសាក្សី គាត់**មិនអាចធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ** ។ ប៉ុន្តែ ដោយសារជនរងគ្រោះតិចតួចណាស់ដែលនឹងត្រូវអញ្ជើញឲ្យមកធ្វើជាសាក្សី អ្នកដែលចង់ធ្វើជាសាក្សីគួរតែចុះឈ្មោះធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ប្រសិនបើចង់ចូលរួមតាមរបៀបណាមួយក្នុងចំណោមរបៀបទាំងពីរនេះ ។

## II. ពាក្យបណ្ដឹង

### អ្នកដែលអាចធ្វើពាក្យបណ្ដឹង

ពាក្យបណ្ដឹងអាចធ្វើឡើងដោយបុគ្គលណាមួយ អង្គការណាមួយ ឬដោយប្រភពផ្សេងទៀតដែលបានឃើញការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញ ឬដែលបានដឹងអំពីឧក្រិដ្ឋកម្មទាំងនោះ ។

### គោលបំណងនៃពាក្យបណ្ដឹង

សហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្ដើមធ្វើការចោទប្រកាន់ដោយផ្អែកលើពត៌មានដែលប្រមូលបាន ឬដោយផ្អែកទៅលើពាក្យបណ្ដឹងណាមួយ ។ ពាក្យបណ្ដឹងបានផ្ដល់ឲ្យសហព្រះរាជអាជ្ញានូវអង្គហេតុដែលពួកគេអាចប្រើប្រាស់ដើម្បី (១).បន្ថែមបទចោទប្រកាន់លើជនជាប់ចោទ ឬដើម្បី (២).ធ្វើការចោទប្រកាន់លើជនជាប់ចោទ ថ្មីទៀត ។

### ពត៌មានដែលចាំបាច់

ក. **អត្តសញ្ញាណរបស់អ្នកធ្វើពាក្យបណ្ដឹង**

ខ. **អាស័យដ្ឋានទំនាក់ទំនងរបស់ម្ចាស់ពាក្យបណ្ដឹង** ។ អង្គជំនុំជម្រះវិសាមញ្ញចង់បានលេខទូរស័ព្ទជាង ប្រសិនបើអាច ។

គ. **កម្មវត្ថុរបស់ពាក្យបណ្ដឹង**

ឃ. **សេចក្ដីសង្ខេបនៃបទចោទប្រកាន់**នៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នេះគួរតែជាការពន្យល់អង្គហេតុទាក់ទងទៅនឹងអ្វីដែលបានកើតឡើងចំពោះជនរងគ្រោះ ។

ង. **ពត៌មានពិស្ដារអំពីសាក្សីសំខាន់**

ច. **ភ័ស្តុតាង**ណាមួយដែលម្ចាស់បណ្ដឹងមាន និង

ង. ការបញ្ជាក់ថាតើម្ចាស់បណ្តឹងចង់ចូលរួមធ្វើជា**ដើមបណ្តឹងរដ្ឋប្បវេណី**ឬទេ ប្រសិនបើសំណុំរឿងនេះនាំទៅដល់ការចាប់ផ្តើមស៊ើបអង្កេតណាមួយ ។

## ការរក្សាភាពសម្ងាត់

គ្រប់ពាក្យបណ្តឹងទាំងអស់នឹងត្រូវរក្សាជាការសម្ងាត់ ។ ប៉ុន្តែ ជានិច្ចកាល វាតែងតែមានករណីដែលថា នៅពេលអង្គជំនុំជម្រះវិសាមញ្ញធ្វើទំនាក់ទំនងជនរងគ្រោះណាមួយតាមរយៈសំបុត្រ ឬទៅជួបផ្ទាល់នៅផ្ទះរបស់គាត់ មនុស្សទាំងឡាយនឹងដឹងថា ជនរងគ្រោះបានទាក់ទងអង្គជំនុំជម្រះវិសាមញ្ញ ។

## ការចុះបញ្ជី

រហូតដល់ពេលដែល**អង្គភាពជនរងគ្រោះ**ត្រូវបានបង្កើតឡើង ទើបព្រះរាជអាជ្ញារទទួលចុះបញ្ជី និងពិនិត្យមើលលើពាក្យបណ្តឹង ។

## លទ្ធផលនៃពាក្យបណ្តឹងដែលត្រូវទទួលយក ឬទាត់ចោល

សហព្រះរាជអាជ្ញារនឹងទទួល និងពិនិត្យមើលពាក្យបណ្តឹងទាំងអស់ ។ ប៉ុន្តែ **ការធ្វើពាក្យបណ្តឹងមិនមែនអាចចាប់ផ្តើមការចោទប្រកាន់ណាមួយដោយស្វ័យប្រវត្តិភ្លាមៗទេ ។** សហព្រះរាជអាជ្ញារ អាចប្រើប្រាស់ឆន្ទានុសិទ្ធិក្នុងការសម្រេចថាតើត្រូវទទួលយក ឬទាត់ចោលពាក្យបណ្តឹងណាមួយ ។ **សហព្រះរាជអាជ្ញារមានកាតព្វកិច្ចត្រូវជូនដំណឹងដល់ម្ចាស់បណ្តឹងអំពីការសម្រេច (ទទួលយក ឬទាត់ចោល) របស់ពួកគេក្នុងរយៈពេល៦០ថ្ងៃ ។**

ប្រសិនបើពាក្យបណ្តឹងណាមួយត្រូវទាត់ចោល វាមិនមែនមានន័យថា ពត៌មាននៅក្នុងពាក្យបណ្តឹងនោះមិនមានប្រយោជន៍ ឬអង្គជំនុំជម្រះវិសាមញ្ញគិតថា ពត៌មានទាំងនោះមិនពិតនោះទេ ។ វាគ្រាន់តែមានន័យថា សហព្រះរាជអាជ្ញារបានផ្តោតលើធនធានស៊ើបអង្កេតមានកំណត់របស់ពួកគេទៅលើតែជនសង្ស័យមួយចំនួនតូច និងទៅលើបទឧក្រិដ្ឋមួយចំនួនតូចដែលពួកគេគិតថាអាចងាយស្រួលបញ្ជាក់ពីទោសកំហុសជាងប៉ុណ្ណោះ ។

# III. ការដាក់បណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

## អ្នកដែលអាចដាក់បណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

មានតែ“ជនរងគ្រោះ”ប៉ុណ្ណោះដែលអាចដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបាន ។ ដើម្បីគោលបំណងចូលរួមនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ពាក្យថា“ជនរងគ្រោះ”មិនមែន

សំដៅទៅរកជនរងគ្រោះទាំងអស់នោះទេ ប៉ុន្តែ ជា“សិល្បៈនៃការប្រើប្រាស់ពាក្យ” ដែលមានន័យថា វាមាននិយមន័យតូចចង្អៀត និងជាក់លាក់ ។

ជនរងគ្រោះនៃបទឧក្រិដ្ឋកម្មណាមួយ នៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញអាចធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី*នៅក្នុងសំណុំរឿង*ដែលទាក់ទងនឹងឧក្រិដ្ឋកម្មនោះ ។ បទឧក្រិដ្ឋកម្មស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមាន ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទប្រល័យពូជសាសន៍ ។ល ។ “សំណុំរឿង”មានន័យថាជាដំណើរការជំនុំជម្រះទៅលើ**ជនជាប់ចោទណាម្នាក់** ឬទៅលើជនជាប់ចោទច្រើននាក់ ប្រសិនបើពួកគេត្រូវចោទប្រកាន់រួមគ្នា ។ នេះមានន័យថា ជនរងគ្រោះម្នាក់អាចចូលរួមតែនៅក្នុងដំណើរការជំនុំជម្រះលើជនណាម្នាក់ដែល**កំពុងស៊ើបអង្កេត**ដោយអង្គជំនុំជម្រះវិសាមញ្ញប៉ុណ្ណោះ ហើយជនរងគ្រោះនោះត្រូវតែប្រាប់អង្គជំនុំជម្រះវិសាមញ្ញថាតើសំណុំរឿងមួយណាដែលខ្លួនចង់ចូលរួម ។

លក្ខណៈសម្បត្តិក្នុងការធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីគឺគឺងតែងជាងលក្ខណៈសម្បត្តិក្នុងការធ្វើពាក្យបណ្តឹង ។ ប៉ុន្តែ **យើងមិនទាន់ដឹងនៅឡើយទេថាតើលក្ខណៈសម្បត្តិចង្អៀត ឬទូលាយប៉ុណ្ណាដែលអង្គជំនុំជម្រះនឹងធ្វើការបកស្រាយនោះទេ ។** ដោយសារមូលហេតុនេះ យើងគួរតែជំរុញអ្នករួចរស់ជីវិតទាំងអស់ឲ្យដាក់ពាក្យសុំធ្វើជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែ យើងក៏គួរតែបញ្ជាក់ប្រាប់ឲ្យបានច្បាស់ថា ជានិច្ចកាល វាតែងតែមានករណីដែលថា អង្គជំនុំជម្រះវិសាមញ្ញនឹងសម្រេចថា រឿងរ៉ាវរបស់គាត់មិនគ្រប់គ្រាន់ដើម្បីភ្ជាប់ទៅនឹងសំណុំរឿងដែលគាត់សុំចូលរួម ។

## នៅពេលណាដែលគេអាចដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបាន

ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីបានគ្រប់ពេលវេលាទាំងអស់ក្នុងអំឡុងពេលស៊ើបអង្កេតនៅក្នុងសំណុំរឿងជាក់លាក់ណាមួយ រហូតដល់ពេលចាប់ផ្តើមជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះនៃសាលាដំបូង ។

## គោលបំណងនៃការដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី

គោលបំណងនៃការដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បីៈ

ក. ចូលរួមក្នុងដំណើរការជំនុំជម្រះព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទដោយគាំទ្រខាងអយ្យការ និង

ខ.  អនុញ្ញាតឲ្យជនរងគ្រោះស្វែងរកការជួសជុលសំណងផ្លូវចិត្ត និងជាសមូហភាព (មិនរួមបញ្ចូលការផ្តល់សំណងជាហិរញ្ញវត្ថុទៅឲ្យបុគ្គលទេ ដូចដែលមានពិភាក្សានៅខាងក្រោម) ។

## ពត៌មានចាំបាច់

ពាក្យបណឹងត្រូវតែធ្វើឡើងដោយប្រើប្រាស់**ទម្រង់ពត៌មានជនរងគ្រោះ** និងត្រូវតែរួមបញ្ចូលនូវពត៌មានដូចខាងក្រោមនេះ

ក. លេខសំណុំរឿងដែលជនរងគ្រោះចង់ចូលរួម ។ បច្ចុប្បន្ននេះ មានសំណុំរឿងចំនួនពីរៈ

កាំង ហ្គេចអ៊ាវ (ឌុច)   - សំណុំរឿងលេខៈ **០០១/១៨-០៧-២០០៧**

នួន ជា   - សំណុំរឿងលេខៈ **០០២/១៩-០៩-២០០៧**

ខ. **ការបញ្ជាក់ស្ថានភាពរបស់អ្នកធ្វើពាក្យបណ្តឹងថាជា«ជនរងគ្រោះ»**

អ្នកដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែផ្តល់ពត៌មានឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចបញ្ជាក់ថាពួកគេជា«ជនរងគ្រោះ»ដូចដែលបានឲ្យនិយមន័យនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

១. ជនរងគ្រោះអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល

២. ព្យសនកម្មរបស់ជនរងគ្រោះត្រូវតែ**បណ្តាលមកពី**ការប្រព្រឹត្តឧក្រិដ្ឋកម្មស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ នេះមានន័យថាជា ការបំពារបំពានធ្ងន់ធ្ងរ, ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ល ។

៣. ព្យសនកម្មរបស់ជនរងគ្រោះត្រូវតែជា**ផលវិបាកដោយផ្ទាល់**នៃបទឧក្រិដ្ឋកម្មដែលចោទប្រកាន់ទៅលើជនជាប់ចោទណាម្នាក់ ។ នេះមានន័យថា គេត្រូវតែបង្ហាញទំនាក់ទំនងរវាងព្យសនកម្មរបស់ជនរងគ្រោះ និង**បទឧក្រិដ្ឋដែលបានចោទប្រកាន់ទៅលើជនជាប់ចោទ** ។

៤. ជនរងគ្រោះត្រូវតែទទួលរងព្យសនកម្ម**ដោយផ្ទាល់** ដែលប្រហែលជាអាចមិនរាប់បញ្ចូលការទាមទារធ្វើឡើង ជាឧទាហរណ៍ ដោយទាយាទរបស់ជនរងគ្រោះផង ។ នេះមានន័យថា កូនរបស់ជនរងគ្រោះប្រហែលជាមិនអាចធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីជំនួសឪពុកម្តាយដែលបានស្លាប់ទៅហើយទេ ។

៥. ជនរងគ្រោះត្រូវតែទទួលរង**ព្យសនកម្មរាងកាយ សម្ភារៈ ឬផ្លូវចិត្ត**

- ***ព្យសនកម្មរូបរាងកាយ***សំដៅលើការខូចខាតលើសារពាង្គកាយ ។
- ***ព្យសនកម្មសម្ភារៈ***សំដៅលើការខូចខាតទ្រព្យសម្បត្តិ ។
- ***ព្យសនកម្មផ្លូវចិត្ត***សំដៅលើការឈឺចាប់ផ្លូវចិត្ត រួមទាំងការបាត់បង់សាច់ញាតិដែលជាជនរងគ្រោះដោយផ្ទាល់នៃឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែ ព្យសនកម្មនេះគឺប្រហែលជាស្ថិតនៅក្នុងលំដាប់មួយចង្អៀតជាង“ព្យសនកម្មស្មារតី” ដូច្នេះ ព្យសនកម្មផ្លូវចិត្តប្រហែលជាតម្រូវឲ្យមានការបង្ហាញខ្លះៗនៃព្យសនកម្ម ឬពិការភាពណាមួយ ។

គ. ***ពត៌មានអំពីបទចោទប្រកាន់***

ឃ. ***អាស័យដ្ឋាន***ដែលជនរងគ្រោះរស់នៅ ឬអាស័យដ្ឋានសមាគមជនរងគ្រោះ ឬអាស័យដ្ឋានមេធាវីរបស់ជនរងគ្រោះ ។ សមាគមជនរងគ្រោះគឺជាអង្គការប្រភេទពិសេសមួយដែលត្រូវតែទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញ ។

ង. ***វិធានការណ៍ការពារ***ណាមួយដែលស្នើសុំដោយជនរងគ្រោះ ដូចជាការការពារអត្តសញ្ញាណរបស់គាត់ ។ នៅក្នុងទម្រង់សម្រាប់បំពេញ មិនមានពត៌មានបែបនេះទេ ដូច្នេះ ទម្រង់មួយដាច់ដោយឡែកគួរតែផ្តល់ឲ្យជនរងគ្រោះបំពេញទាក់ទងនឹងពត៌មាននេះ ។

ច. ***ភ័ស្តុតាង***ណាមួយដែលជនរងគ្រោះមានដែលអាចបង្ហាញពីព្យសនកម្មដែលខូចខាត ឬបង្ហាញពីទោសកំហុស ឬពីជនសមគំនិត ។

## **ការជូនដំណឹង**

ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានបដិសេធន៍ ប្រសិនបើមិនបំពេញតាមលក្ខ័ណ្ឌទាំងនេះ ។ សេចក្តីសម្រេចបដិសេធន៍នេះអាចប្តឹងជំទាស់បាន ។

## **ផលវិបាកនៃការចូលរួម**

ប្រសិនបើចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះត្រូវបានគេចាត់ទុកថាជា“ភាគី”មួយនៅក្នុងដំណើរការជំនុំជម្រះព្រហ្មទណ្ឌប្រឆាំងនឹងជនជាប់ចោទណាម្នាក់ ។ ***“ភាគី” មិនអាចធ្វើជាសាក្សីទេ ។*** ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវសាកសួរដោយអង្គជំនុំជម្រះវិសាមញ្ញ ហើយរឿងរ៉ាវរបស់ពួកគេនឹងត្រូវបញ្ចូលទៅក្នុងឯកសារផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ដើមបណ្តឹងរដ្ឋប្បវេណីក៏អាច

ស្នើសុំសហចៅក្រមស៊ើបអង្កេតឲ្យសាកសួរគាត់ សាកសួរសាក្សី ទៅពិនិត្យមើលកន្លែងណាមួយ និង ប្រមូលភស្តុតាងជំនួសគាត់ ។ សំណើរនេះអាចត្រូវបដិសេធន៍ ឬទាត់ចោល ។

ដើមបណ្តឹងរដ្ឋប្បវេណីអាចបោះបង់ការសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនេះបានគ្រប់ពេល ។

## ការដំណាងនៅក្នុងដំណើរការជំនុំជម្រះ

ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានមេធាវី ឬទទួលបានការការពារដោយមេធាវី ឬដោយសមាគមជនរងគ្រោះក្នុងនាមជាផ្នែកមួយនៃជនរងគ្រោះមួយក្រុម ។ សមាគមជនរងគ្រោះគឺជាអង្គការជនរងគ្រោះប្រភេទពិសេសមួយដែលត្រូវតែទទួលស្គាល់ជាផ្លូវការដោយអង្គភាពជនរងគ្រោះ ។ អង្គភាពជនរងគ្រោះអាចផ្តល់ឈ្មោះមេធាវី និងសមាគមជនរងគ្រោះដែលមាន ។ អង្គភាពជនរងគ្រោះក៏នឹងជួយរៀបចំភាពតំណាងជាក្រុមផងដែរ ។

## ការជួសជុលសំណង

មានតែដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះដែលនឹងអាចទទួលបានការជួសជុលសំណង ។ ការជួសជុលសំណងនឹង**មិន**ផ្តល់ទៅឲ្យបុគ្គលនោះទេ ប៉ុន្តែ ផ្តល់ជា«សមូហភាព» និង«ផ្លូវចិត្ត» ។ «ផ្លូវចិត្ត» មានន័យស្រដៀងគ្នាទៅនឹង«និមិត្តរូប» ។ សំណងរបៀបនេះអាចមានទម្រង់ដូចខាងក្រោមៈ

ក. ដីកាបង្គាប់ឲ្យបោះពុម្ពសាលក្រមនៅក្នុងសារពត៌មានសមរម្យទាំងឡាយ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដោយប្រើប្រាស់ថវិការបស់ជនដែលរកឃើញថាមានកំហុសនោះ ។

ខ. ដីកាបង្គាប់ឲ្យផ្គត់ផ្គង់ថវិកាទៅឲ្យសកម្មភាពមិនរកប្រាក់ចំណូលណាមួយ ឬសេវាកម្មមិនរកប្រាក់ចំណូលណាមួយដែលផ្តល់ផលប្រយោជន៍ដល់ជនរងគ្រោះ ។

គ. ទម្រង់សមរម្យផ្សេងៗទៀតនៃការជួសជុសសំណង ។ នេះអាចរួមមានរបស់មួយលំដាប់ធំ ប៉ុន្តែ មិនមែនជា**លុយកាក់**ទេ ។ ឧទាហរណ៍ វាអាចរួមមានការសាងសង់បូជនីយដ្ឋានជាតិ ឬការសាងសង់គ្លីនិកសុខភាពផ្លូវចិត្ត ។

# IV. អង្គភាពជនរងគ្រោះ

អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញគឺជាកន្លែងសម្រាប់ទំនាក់ទំនងតែមួយគត់សម្រាប់ជនរងគ្រោះដែលដាក់ពាក្យសុំចូលរួមនៅក្នុងដំណើរការជំនុំជម្រះ ។ អាស័យដ្ឋានរបស់អង្គភាពជនរងគ្រោះ :

អង្គភាពជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញ

ផ្លូវជាតិលេខ៤

សង្កាត់ចោមចៅ ខណ្ឌដង្កោ ក្រុងភ្នំពេញ ប្រទេសកម្ពុជា
អ៊ីម៉េលៈ victimsunit@eccc.gov.kh

ប៉ុន្តែ អង្គភាពជនរងគ្រោះមិនទាន់បង្កើតឡើងនៅឡើយទេ។ នៅពេលដែលអង្គភាពនេះត្រូវបានបង្កើតឡើង ជនរងគ្រោះគួរតែដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់ក្រឡាបញ្ជីនៅក្នុងការិយាល័យរបស់សហព្រះរាជអាជ្ញារ និងដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីដោយផ្ទាល់ទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត។

អង្គភាពជនរងគ្រោះនឹងផ្តល់ជំនួយផ្នែករដ្ឋបាលនៅក្នុងការរៀបចំពាក្យបណ្តឹង និងពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។ អង្គភាពជនរងគ្រោះក៏នឹងជួយជនរងគ្រោះស្វែងរកមេធាវី និងសមាគមជនរងគ្រោះ។ **អង្គភាពជនរងគ្រោះនឹងមិនផ្តល់ជំនួយហិរញ្ញវត្ថុ ឬជំនួយផ្នែកច្បាប់ទេ។**

ពត៌មានបន្ថែមសូមទាក់ទង
វ៉ាន់ថាន់ ពៅដារ៉ា
នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា
ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ
ក្រុងភ្នំពេញ
ទូរស័ព្ទលេខ ៖ ០២៣ ២១១ ៨៧៥
ទូរស័ព្ទដៃលេខ ៖ ០១២ ៨៤៦ ៥២៦
អ៊ីម៉ែល ៖ truthpdara@yahoo.com
គេហទំព័រ www.dccam.org

ប្រែសម្រួលជាភាសាខ្មែរដោយជី ទេវិទ្ធិ មជ្ឈមណ្ឌលឯកសារកម្ពុជា